**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...................ន. គ. ស .......

ថ្ងៃអង្គារ ៦ កើត ខែចេត្រ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ,ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើសក្រុមហ៊ុនជំនាញត្រួតពិនិត្យលើការបកប្រែភាសាអង់គ្លេសទៅជាខេមរភាសា លើឯកសារស្តង់ដាសវនកម្ម ស្តង់ដាគណនេយ្យ និងស្តង់ដាពាក់ព័ន្ធវិស័យគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម** (ន.គ.ស.) គឺជាស្ថាប័នតែមួយគត់នៅកម្ពុជាដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារលើការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ប្រកបដោយការជឿទុកចិត្តពីស្ថាប័នសាធារណៈ ស្ថាប័នឯកជន គណនេយ្យករ សវនករ និងសាធារណជន។ ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន ន.គ.ស. បានដាក់ចេញនូវផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល១០ឆ្នាំ (២០២១ -២០៣០)។ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសក្នុង ការប្រែក្លាយខ្លួនទៅជាអង្គភាពមួយដែលមានភាពធន់ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើនិយ័តកម្ម និងគ្រប់គ្រងវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ក្នុងគោលដៅបង្កើតនូវប្រព័ន្ធគណនេយ្យរបស់ជាតិមួយ ដែលមានភាពរឹងមាំ មានតម្លាភាព និងអាចទុកចិត្តបាន។ វិសាលភាព មុខងារភារកិច្ចរបស់ ន.គ.ស. ក្នុងដាក់ឱ្យអនុវត្តស្តង់ដាបច្ចេកទេសនៅកម្ពុជាមានទំហំធំ ដោយគ្របដណ្តប់ ទាំងវិស័យសាធារណៈ និងទាំងវិស័យឯកជនគ្រប់ប្រភេទអាជីវកម្ម ព្រមទាំងអង្គភាពមិនស្វែងរកប្រាក់ចំណេញផងដែរ។ ន.គ.ស. បានធ្វើការបកប្រែស្តង់ដាគណនេយ្យ និងស្តង់ដាសវនកម្ម បានរួចរាល់ក្នុងកម្រិតបច្ចេកទេស ប៉ុន្តែអត្ថបទឯកសារទាំងអស់នោះមានលក្ខណៈបច្ចេកទេសខ្ពស់ ដែលតម្រូវឱ្យមានអ្នកជំនាញការខាងក្រៅដែលមានវិជ្ជាជីវៈជាអាជីពលើការបកប្រែ ដើម្បីធ្វើការត្រួតពិនិត្យលើឯកសារស្តង់ដាដែលបានបកប្រែរួចរាល់ទាំងអស់នោះជាចុងក្រោយ ដើម្បីឱ្យឯកសារស្តង់ដាដែលបានដាក់ចេញជាខេមរៈភាសាមានភាពត្រឹមត្រូវគត់មត់ និងមានប្រសិទ្ធភាពខ្ពស់សម្រាប់ប្រើប្រាស់ជាផ្លូវការ។

ក្នុងន័យនេះ ន.គ.ស. សូមប្រកាសជ្រើសរើសក្រុមហ៊ុនជំនាញត្រួតពិនិត្យលើការបកប្រែភាសាអង់គ្លេសទៅជាខេមរភាសា ដែលមានគុណវុឌ្ឍិដូចខាងក្រោម៖

### ១. លក្ខខណ្ឌគុណវុឌ្ឍិ

ក្រុមហ៊ុនដែលអាចចូលរួមក្នុងការដេញថ្លៃបាន លុះត្រាតែជាក្រុមហ៊ុនដែល៖

- បានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម និងនៅអគ្គនាយកដ្ឋានពន្ធដារ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បានអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មពេញលេញ
- មានក្រុមការងារស្នូលត្រូវមានវិញ្ញាបនបត្រវិជ្ជាជីវៈច្បាស់លាស់ (ACCA/CPA) ឬសញ្ញាបត្រប្រហាក់ប្រហែលក្នុងវិស័យគណនេយ្យនិងសវនកម្ម
- មានក្រុមការងារមានជំនាញភាសាខ្មែរ និងភាសាអង់គ្លេសកម្រិតខ្ពស់ ជាពិសេសលើការបកប្រែ ឬពិនិត្យឯកសារបច្ចេកទេសស្តង់ដាគណនេយ្យនិងសវនកម្ម និងឯកសារច្បាប់ពាក់ព័ន្ធ
- ជាប្រភេទក្រុមហ៊ុនផ្តល់សេវាបកប្រែមានលក្ខណៈស្តង់ដានិងមានការទទួលស្គាល់ក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ
- មានបទពិសោធន៍ក្នុងការបកប្រែឯកសារពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម យ៉ាងតិចណាស់១០ឆ្នាំ
- មានបទពិសោធន៍ក្នុងការសហការជាមួយស្ថាប័នរដ្ឋ ដៃគូអភិវឌ្ឍន៍ ឬសមាគមវិជ្ជាជីវៈ នឹងត្រូវទទួលបានអាទិភាព
- ការបានចូលរួមក្នុងកិច្ចអភិវឌ្ឍន៍វិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា ត្រូវបានលើកទឹកចិត្ត។

## ២. លក្ខខណ្ឌយោងការងារ

- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ពាក្យពេចន៍ និងខ្លឹមសារទាំងស្រុងរវាងឯកសារដើម នៃស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធ (ជាភាសាអង់គ្លេស) និងឯកសារបកប្រែ (ជាភាសាខ្មែរ)
- កែសម្រួលពាក្យបច្ចេកទេសដោយធានាបាននូវការប្រើប្រាស់ពាក្យបច្ចេកទេសឱ្យមានភាពស៊ីសង្វាក់គ្នា នឹងអនុលោមទៅតាមសន្ទានុក្រមគណនេយ្យនិងសវនកម្មរបស់ ន.គ.ស.
- កែសម្រួលអក្ខរាវិរុទ្ធ និងទម្រង់ឃ្លាប្រយោគ និងរៀបចំទម្រង់អត្ថបទឱ្យមានរបៀបរៀបរយ
- ផ្តល់ជាអនុសាសន៍ ឬបកស្រាយបន្ថែមក្នុងករណីមានចំនុចមិនច្បាស់លាស់ ឬពាក្យបច្ចេកទេសស្មុគស្មាញដែលតម្រូវឱ្យមានការសម្រេចចិត្តពីថ្នាក់ដឹកនាំ

## ៣. កម្រៃ

កម្រៃសម្រាប់ត្រួតពិនិត្យលើការបកប្រែស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម ត្រូវបានបើកចំហរសម្រាប់ការចរចារ។

## ៤. រយៈពេលសម្រាប់ត្រួតពិនិត្យលើការបកប្រែស្តង់ដា

ការត្រួតពិនិត្យលើការបកប្រែស្តង់ដាខាងលើនេះមានរយៈពេលក្រោម ឬលើស៣ (បី) ខែ ទៅតាមឯកសារជាក់ស្តែង។ ក្នុងករណីមានការបន្ត ឬពន្យារពេលក្នុងការបកប្រែបន្ទាប់ពីការព្រមព្រៀង នោះនឹងត្រូវមានការពិភាក្សានិងចរចាបន្ត។ កិច្ចសន្យានេះនឹងត្រូវបង្កើតឡើងរវាង ន.គ.ស ជា មួយនឹងក្រុមហ៊ុនដែលបានទទួលជោគជ័យក្នុងការដេញថ្លៃ។

## ៥. ការដាក់ពាក្យ

ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ សូមផ្ញើរសេចក្តីចំណាប់អារម្មណ៍មក និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) តាមរយៈអ៊ីម៉ែល general_affairs_dept@acar.gov.kh និង h.sokunthea@acar.gov.kh ត្រឹមថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦ ដោយដាក់ទាំងសំណើបច្ចេកទេស (Technical Proposal) និងសំណើហិរញ្ញវត្ថុ (Financial Proposal)។

សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទាក់ទងតាមអាសយដ្ឋាន ឬលេខទូរស័ព្ទ ដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី១ ផ្លូវលេខ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទទាក់ទង និងតេឡេក្រាម ៖ ០៦៩ ៧៨៣ ៩៣៦ / ០១២ ៧៩៣ ៣៩៨

**និយ័តករគណនេយ្យនិងសវនកម្ម**